**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

*Kingdom of Wonder*

*feel the warmth*

**ក្រសួងទេសចរណ៍**

លេខ ០០៦ សណន

ថ្ងៃ ៣ រោច ខែ អស្សុជ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តភារកិច្ចនៃការចុះផ្សាយលិខិតបទដ្ឋានគតិយុត្តទេសចរណ៍ក្នុងរាជកិច្ច

យោងសារាចរលេខ ០៨ សរ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីភារកិច្ចចុះផ្សាយក្នុងរាជកិច្ចរបស់រាជរដ្ឋាភិបាល បានតម្រូវឱ្យគ្រប់លិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពអនុវត្តទូទៅត្រូវចុះផ្សាយក្នុងរាជកិច្ច។ ក្នុងន័យនេះ ក្រសួងទេសចរណ៍ សូមណែនាំដូចខាងក្រោម៖

១. រាល់លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទេសចរណ៍ ត្រូវឆ្លងកាត់ការត្រួតពិនិត្យពីនាយកដ្ឋាននីតិកម្មជាមុនសិន មុននឹងដាក់ជូនរដ្ឋមន្ត្រីចុះហត្ថលេខា ដើម្បីជៀសវាងនូវរាល់កំហុសនានា ដែលកើតឡើងជាយថាហេតុក្នុងការចុះផ្សាយក្នុងសៀវភៅរាជកិច្ច។

២. អង្គភាពសាមី ត្រូវប្រញាប់សកាន់ផ្ញើរាល់លិខិតបទដ្ឋានគតិយុត្ត ដែលបានប្រថាប់ត្រារួចរាល់ របស់ក្រសួងទេសចរណ៍មកនាយកដ្ឋាននីតិកម្មចំនួន២ (ពីរ) ច្បាប់ មានត្រាក្រហម។

៣. នាយកដ្ឋាននីតិកម្ម ត្រូវរៀបចំបញ្ជូនលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងទេសចរណ៍ទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចុះផ្សាយក្នុងសៀវភៅរាជកិច្ច។

៤. នាយកដ្ឋាននីតិកម្ម ត្រូវរៀបចំ ចងក្រង តម្កល់ ចែកចាយ និងផ្សព្វផ្សាយ រាល់លិខិតបទដ្ឋានគតិយុត្តទេសចរណ៍ ឱ្យបានទូលំទូលាយដល់ថ្នាក់ដឹកនាំ និងអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល ៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និង សហប្រតិបត្តិការអន្តរជាតិ
- អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- វិទ្យាស្ថានជាតិទេសចរណ៍
- សាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍
- អគ្គាធិការដ្ឋាន
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងទេសចរណ៍
- ឯកសារ កាលប្បវត្តិ